តម្លាភាពកម្ពុជា
TRANSPARENCY INTERNATIONAL
Cambodia

# Business Integrity Country Agenda (BICA) Assessment

# Public Sector Brief

Cambodia has a sound legal and policy framework that is largely in line with international standards, particularly the 2010 adoption of the Law on Anti-Corruption. The Royal Government of Cambodia's continued willingness to align Cambodia's legislation with international treaties and agreements resulted in significant improvements in human development, GDP growth and substantial foreign investment. New legislative reforms in taxation and accounting standards have improved Cambodia's ability to generate tax revenues and encourage businesses to operate with greater transparency. Areas where improvements in legislation is needed are in the protection of whistleblowers, better regulation of market competition and legislation regulating influences on political parties. Despite the development of robust legislation, the implementation of these frameworks is an ongoing challenge. Agencies entrusted with implementing existing laws are not uniformly effective. Of note, is the increased amount of money laundered and illicit financial flows in Cambodia in recent years despite available legislation and institutional oversight from banking and governance institutions. Some Ministries and provincial level governance bodies are making great strides in transparency and integrity, especially in areas such as taxation and procurement. Others lack transparency, oversight and training and have lower operational capacities that interfere with their ability to enforce adopted standards. There are also differing capacities between urban and rural populations to administer a more regulated operational framework in doing business.

The effectiveness and ineffectiveness of existing legal frameworks in Cambodia stems from several factors:

- Capacity of enforcement agencies to implement the laws;
- Capacities among domestic firms to develop their business in compliance with the law;
- Inadequate coordination between nationally directed projects and sub-national management;
- The challenge of competing for foreign investment while shifting the business environment;
- Lack of political will to call out lagging institutions on sensitive issues in combatting corruption.

The public and private sectors have historically been very interwoven in Cambodia, making the creation of an open, fair, and transparent business environment all the more challenging. The post-conflict context in Cambodia remains relevant in the discussion of greater transparency and accountability in the public sector. Governance bodies at the national and sub-national level must transition from relying on informal and patronage networks that exclude large portions of the population to one that encourages civic participation and the benefits of a business environment with greater transparency and integrity. Destabilising systems of patronage requires a delicate balance of increasing the capacity of actors who were formerly excluded and limiting behaviours that result in opacity and lack of due process from actors who enjoy the majority of the table. In an economy reliant on imports and exports, Cambodia must also increase its competitiveness between two much larger economies (Thailand and Vietnam) in an environment

The BICA Assessment Report is a baseline assessment of public, private and civil society sector efforts to promote business integrity, particularly accountability, transparency, and integrity in business practices. This report seeks to further understand the factors and actions that can increase business integrity in Cambodia, in order to facilitate public, private, and civil society efforts to diminish corruption.

where transparency and public accountability are not universally prioritised. As Cambodia transitions from an aid reliant low-income economy to a lower middle-income economy, the State must also transition its governance measures to reduce reliance on informal systems and closed patronage networks.

## Key Recommendations

- Expedite the promulgation of key pieces of legislation to increase transparency and accountability such as the draft law on competition; the draft law on the protection of reporting persons; the draft law on the protection of experts, victims and witnesses and provide operational benchmarks for both public and private sectors that are in line with international standards.
    - Create an online legal database of all laws in Cambodia, with translation of all new laws into English, in order to increase awareness of the legal framework in Cambodia and the ability of civil society organisations to monitor legal developments and their implementation.
    - The MoJ and RGC should amend legislation in order to require Judges at all levels of court to publish their decisions and reasoning and ensure that standards are established for open court proceedings.
- Continue to create an environment of integrity within the ACU and a better relationship between the ACU and the public by i) providing an anonymous mechanism for complaints against ACU investigators (i.e. through the online complaint mechanism administered by the Ministry of Civil Service) ii) making public the general process by which ACU investigations result in charges of corruption iii) providing mechanisms of due process and appeal for public allegations of corruption iv) publishing the terms and conditions of the MoUs that the ACU has signed with Cambodian and international companies and other ministries.
- Strengthen the effectiveness of CAFIU in investigating and sanctioning instances of suspected money-laundering and in coordinating and consistently reviewing financial institutions.
- Strengthen anti-corruption legislation within the Law on Taxation and the Law on Customs and link the Anti-Corruption Law with tax and customs regulations through a sub-decree.
    - Disclose all official tariffs levied by the GDCE, the GDT, and other officials publicly, and sanction any officers who request informal tariff payments. Disallow changes to tariff schemes without timely notification to the public.
    - Disclose all Qualified Investment Projects (QIPs) publicly and provide a list of beneficiaries and aggregated data regarding tax incentives and other benefits under the QIP program.
- Increase online and one-window public services to reduce bureaucratic burdens and costs associated with doing business in Cambodia, particularly for SMEs, and coordination, responsiveness and accountability from relevant Ministries.

***Transparency International Cambodia***
*#3, Street 390, Sangkat BoengKengkang 3,*
*Khan Chamkarmorn,*
*Phnom Penh, Kingdom of Cambodia*

( +855 ) 23 214 430

*Website: www.ticambodia.org*
*Global website: www.transparency.org*

តម្លាភាពកម្ពុជា
TRANSPARENCY INTERNATIONAL Cambodia

# ការវាយតម្លៃអំពីសុចរិតភាពធុរកិច្ចថ្នាក់ជាតិ

# សេចក្តីសង្ខេបស្តីពីវិស័យសាធារណៈ

ប្រទេសកម្ពុជាមានក្របខ័ណ្ឌច្បាប់ និងគោលនយោបាយដ៏ត្រឹមត្រូវមួយ ដែលស្របតាមបទដ្ឋានអន្តរជាតិ ជាពិសេសការអនុម័តច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយនៅឆ្នាំ២០១០។ រាជរដ្ឋាភិបាលកម្ពុជា បន្តមានឆន្ទៈក្នុងការតម្រង់ទិសបទប្បញ្ញត្តិរបស់កម្ពុជា ឱ្យស្របជាមួយសន្ធិសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិនានា ដែលនាំមកនូវការរីកចម្រើនយ៉ាងសំខាន់ ក្នុងការអភិវឌ្ឍធនធានមនុស្ស កំណើនផលិតផលក្នុងស្រុកសរុប និងការវិនិយោគបរទេសយ៉ាងច្រើន។ កំណែទម្រង់ច្បាប់ថ្មីៗនៅក្នុងវិស័យពន្ធដារ និងស្តង់ដារគណនេយ្យ ក៏បានពង្រឹងសមត្ថភាពរបស់ប្រទេសកម្ពុជា ក្នុងការបង្កើនប្រាក់ចំណូលពន្ធ និងការលើកទឹកចិត្តឱ្យអាជីវកម្មធ្វើប្រតិបត្តិការដោយតម្លាភាព។ ចំណុចមួយចំនួននៃច្បាប់ដែលត្រូវធ្វើការកែលម្អរួមមានការការពារអ្នករាយការណ៍ ការធ្វើឱ្យប្រសើរឡើងនូវបទប្បញ្ញត្តិស្តីពីការប្រកួតប្រជែងទីផ្សារ និងច្បាប់កំណត់ការជះឥទ្ធិពលលើគណបក្សនយោបាយ។ ថ្វីបើច្បាប់មានការអភិវឌ្ឍយ៉ាងរឹងមាំក៏ដោយ ក៏ការអនុវត្តក្របខ័ណ្ឌច្បាប់ទាំងនេះនៅបន្តជួបបញ្ហាប្រឈមមួយចំនួន។ ភ្នាក់ងារទាំងឡាយ ដែលមានភារកិច្ចអនុវត្តច្បាប់ ដែលមានស្រាប់ក៏នៅតែមិនមានប្រសិទ្ធភាពដូចគ្នា។ គេកត់សម្គាល់ឃើញថាចំនួនទឹកប្រាក់ពីការលាងសម្អាតប្រាក់ និងលំហូរហិរញ្ញវត្ថុខុសច្បាប់បានកើនឡើងនៅក្នុងប្រទេសកម្ពុជានាប៉ុន្មានឆ្នាំថ្មីៗនេះ ទោះបីជាមានច្បាប់ និងស្ថាប័នត្រួតពិនិត្យសម្រាប់វិស័យធនាគារ និងអភិបាលកិច្ចក៏ដោយ។ ក្រសួង និងស្ថាប័នអភិបាលកិច្ចថ្នាក់ខេត្តខ្លះ កំពុងខិតខំយ៉ាងខ្លាំងក្នុងការលើកកម្ពស់តម្លាភាព និងសុចរិតភាព ជាពិសេសនៅក្នុងវិស័យផ្សេងៗដូចជាពន្ធដារ និងលទ្ធកម្មជាដើម។ ស្ថាប័នផ្សេងទៀតខ្វះតម្លាភាពការត្រួតពិនិត្យ និងការបណ្តុះបណ្តាល ហើយមានសមត្ថភាពប្រតិបត្តិការទាប ដែលរារាំងដល់សមត្ថភាពរបស់ពួកគេក្នុងការអនុវត្តបទដ្ឋានដែលបានអនុម័តរួចហើយ។ ក្នុងនោះដែរប្រជាជននៅទីក្រុង និងប្រជាជននៅជនបទក៏មានគម្លាតសមត្ថភាព ក្នុងការគ្រប់គ្រងក្របខ័ណ្ឌប្រតិបត្តិការដែលមានបទប្បញ្ញត្តិច្រើនក្នុងការធ្វើអាជីវកម្ម។ ប្រសិទ្ធភាព និងកង្វះប្រសិទ្ធភាពនៃក្របខ័ណ្ឌច្បាប់ដែលមានស្រាប់នៅកម្ពុជាកើតចេញពីកត្តាជាច្រើនដូចជា៖

- សមត្ថភាពរបស់ទីភ្នាក់ងារអនុវត្តច្បាប់នានា ក្នុងការអនុវត្តច្បាប់
- សមត្ថភាពរបស់ក្រុមហ៊ុនក្នុងស្រុកក្នុងការអភិវឌ្ឍអាជីវកម្មរបស់ពួកគេឱ្យស្របតាមច្បាប់។
- កង្វះការសម្របសម្រួល រវាងគម្រោងថ្នាក់ជាតិ និងការគ្រប់គ្រងថ្នាក់ក្រោមជាតិ។
- បញ្ហាប្រឈមនៃការចូលរួមប្រកួតប្រជែងក្នុងការទាក់ទាញការវិនិយោគបរទេស ខណៈដែលមានការផ្លាស់ប្តូរបរិយាកាសធុរកិច្ច។
- កង្វះឆន្ទៈនយោបាយ ដើម្បីអំពាវនាវឱ្យស្ថាប័នដែលអសកម្មក្នុងការដោះស្រាយបញ្ហារសើប ឱ្យចូលរួមប្រយុទ្ធប្រឆាំងអំពើពុករលួយ។

វិស័យសាធារណៈ និងវិស័យឯកជន មានទំនាក់ទំនងជំពាក់ជំពិនតាំងពីយូរណាស់មកហើយនៅប្រទេសកម្ពុជា ដែលធ្វើឱ្យការបង្កើតបរិយាកាសធុរកិច្ចដែលបើកចំហ យុត្តិធម៌ និងតម្លាភាពរឹតតែពិបាកជាងមុន។ បរិបទក្រោយជម្លោះនៅកម្ពុជានៅតែស្ថិតក្នុងកិច្ចពិភាក្សាស្តីពីការពង្រឹងតម្លាភាព និងគណនេយ្យភាពនៅក្នុងវិស័យសាធារណៈ។ ស្ថាប័នអភិបាលកិច្ចនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវតែផ្លាស់ប្តូរពីការពឹងផ្អែកលើបណ្តាញក្រៅផ្លូវការ និងខ្សែបណ្តាញដែលមិនរាប់បញ្ចូលប្រជាពលរដ្ឋមួយភាគធំ ទៅជាបណ្តាញមួយដែលលើកទឹកចិត្តឱ្យមានការចូលរួមពីពលរដ្ឋ និងអត្ថប្រយោជន៍នៃបរិយាកាសធុរកិច្ចដែលមានតម្លាភាព និងសុចរិតភាព។

របាយការណ៍ស្តីពី "ការវាយតម្លៃអំពីសុចរិតភាពធុរកិច្ចថ្នាក់ជាតិ" គឺជាការវាយតម្លៃជាមូលដ្ឋាន ដែលធ្វើការវិភាគទៅលើកិច្ចខិតខំប្រឹងប្រែង របស់វិស័យឯកជន វិស័យសាធារណៈ និងសង្គមស៊ីវិលក្នុងការពង្រឹងសុចរិតភាពធុរកិច្ច ជាពិសេស គណនេយ្យភាព តម្លាភាព និងសុចរិតភាពនៅពេលបំពេញធុរកិច្ច។ របាយការណ៍នេះ ផ្តល់ការយល់ដឹងបន្ថែមអំពី កត្តា និងសកម្មភាពការងារដែលអាចជួយបង្កើនសុចរិភាពធុរកិច្ចនៅក្នុងប្រទេសកម្ពុជា ដើម្បីសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងរបស់វិស័យសាធារណៈ វិស័យឯកជន និងសង្គមស៊ីវិលក្នុងការលុបបំបាត់អំពើពុករលួយ។

ដើម្បីលុបបំបាត់ប្រព័ន្ធគាំទ្រ វាទាមទារឱ្យមានតុល្យភាពដោយបង្កើនសមត្ថភាពរបស់អ្នកដែលគេមិនរាប់បញ្ចូលពីមុនមក និងដាក់កម្រិតលើអាកប្បកិរិយាចំពោះអ្នក ដែលទទួលបានផលប្រយោជន៍ភាគច្រើន ដែលនាំឱ្យមានភាពមិនច្បាស់លាស់ និងកង្វះនៃដំណើរការ។ នៅក្នុងសេដ្ឋកិច្ចមួយដែលពឹងផ្អែកលើការនាំចេញ និងនាំចូល កម្ពុជាក៏ត្រូវបង្កើនការប្រកួតប្រជែងជាមួយប្រទេសសេដ្ឋកិច្ចធំៗពីរទៀត (ប្រទេសថៃ និងវៀតណាម) ស្របពេលដែលតម្លាភាព និងគណនេយ្យភាពសាធារណៈ មិនត្រូវបានផ្តល់អាទិភាពជាសកល។ នៅពេលប្រទេសកម្ពុជាផ្លាស់ ប្តូរពីសេដ្ឋកិច្ចចំណូលទាបដែលពឹងផ្អែកលើជំនួយបរទេស ទៅជាសេដ្ឋកិច្ចដែលមានចំណូលមធ្យមកម្រិតទាបនោះ រដ្ឋក៏ត្រូវផ្លាស់ប្តូរវិធានការអភិបាលកិច្ចរបស់ខ្លួនដើម្បីកាត់បន្ថយការពឹងផ្អែកលើប្រព័ន្ធមិនផ្លូវការ និងខ្សែបណ្តាញផងដែរ។

## អនុសាសន៍សំខាន់ៗ

- ពន្លឿនឱ្យមានការអនុម័តច្បាប់សំខាន់ៗ ដើម្បីបង្កើនតម្លាភាព និងគណនេយ្យភាព ដូចជាសេចក្តីព្រាងច្បាប់ស្តីពីការប្រកួតប្រជែង សេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារអ្នករាយការណ៍ សេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារអ្នកជំនាញ ជនរងគ្រោះ និងសាក្សី និងផ្តល់នូវគោលចំណុចប្រតិបត្តិការសម្រាប់វិស័យសាធារណៈ និងឯកជនដែលស្របតាមបទដ្ឋានអន្តរជាតិ។
    - បង្កើតមូលដ្ឋានទិន្នន័យច្បាប់ទាំងអស់នៅកម្ពុជាតាមអនឡាញ ដោយធ្វើការបកប្រែច្បាប់ថ្មីៗទាំងអស់ជាភាសាអង់គ្លេសដើម្បីបង្កើនការយល់ដឹងអំពីក្របខ័ណ្ឌច្បាប់នៅកម្ពុជា និងសមត្ថភាពរបស់អង្គការសង្គមស៊ីវិលដើម្បីតាមដានការអភិវឌ្ឍច្បាប់ និងការអនុវត្តច្បាប់ទាំងនោះ។
    - ក្រសួងយុត្តិធម៌ និងរាជរដ្ឋាភិបាលកម្ពុជា គួរតែធ្វើវិសោធនកម្មច្បាប់ ដើម្បីតម្រូវឱ្យចៅក្រមនៅគ្រប់លំដាប់ថ្នាក់នៃតុលាការ បោះពុម្ពផ្សាយសេចក្តីសម្រេច និងមូលហេតុរបស់ពួកគេ និងដើម្បីធានាថាបទដ្ឋាននានា ត្រូវបានបង្កើតឡើងសម្រាប់នីតិវិធីតុលាការដោយបើកចំហ។
- បន្តបង្កើតបរិយាកាសសុចរិតភាព នៅក្នុងអង្គភាពប្រឆាំងអំពើពុករលួយ និងទំនាក់ទំនងដែលល្អជាងមុនរវាងអង្គភាព និងសាធារណជន តាមរយៈ ១)ការផ្តល់យន្តការអនាមិកសម្រាប់បណ្តឹងប្រឆាំងនឹងអ្នកស៊ើបអង្កេតរបស់អង្គភាពប្រឆាំងអំពើពុករលួយ (ឧទាហរណ៍៖ តាមរយៈយន្តការបណ្តឹងតាមអនឡាញ ដែលគ្រប់គ្រងដោយក្រសួងមុខងារសាធារណៈ) ២)ការប្រកាសជាសាធារណៈអំពីដំណើរការទូទៅ នៃការស៊ើបអង្កេតរបស់អង្គភាពប្រឆាំងអំពើពុករលួយ ពាក់ព័ន្ធនឹងករណីអំពើពុករលួយ ៣) ការផ្តល់យន្តការនៃដំណើរការត្រឹមត្រូវ និងបណ្តឹងតវ៉ានៃការចោទប្រកាន់ជាសាធារណៈអំពីអំពើពុករលួយ និង ៤) ការបោះពុម្ពផ្សាយនូវខ្លឹមសារ និងលក្ខខណ្ឌនៃអនុស្សរណៈនៃការយោគយល់គ្នា ដែលអង្គភាពប្រឆាំងអំពើពុករលួយ បានចុះហត្ថលេខាជាមួយក្រុមហ៊ុនក្នុងស្រុក ក្រុមហ៊ុនអន្តរជាតិ និងក្រសួងនានា។
- ពង្រឹងប្រសិទ្ធភាពនៃអង្គភាពស៊ើបអង្កេតហិរញ្ញវត្ថុកម្ពុជា ក្នុងការស៊ើបអង្កេត និងការដាក់ទណ្ឌកម្មចំពោះករណីលាងសម្អាតប្រាក់ដែលគួរឱ្យសង្ស័យ និងក្នុងការសម្របសម្រួល និងត្រួតពិនិត្យស្ថាប័នហិរញ្ញវត្ថុជាប្រចាំ។
- ពង្រឹងច្បាប់ប្រឆាំងអំពើពុករលួយនៅក្នុងច្បាប់ស្តីពីពន្ធដារ និងច្បាប់ស្តីពីគយ ហើយផ្សារភ្ជាប់ច្បាប់ប្រឆាំងអំពើពុករលួយជាមួយបទប្បញ្ញត្តិពន្ធដារ និងគយតាមរយៈអនុក្រឹត្យ។
    - បើកចំហពន្ធគយផ្លូវការទាំងអស់ដែលប្រមូលដោយ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងដោយមន្ត្រីដទៃទៀតជាសាធារណៈ ហើយដាក់ទណ្ឌកម្មដល់មន្ត្រីទាំងឡាយណាដែលស្នើសុំការបង់ពន្ធក្រៅផ្លូវការ។ មិនអនុញ្ញាតឱ្យមានការផ្លាស់ប្តូរគម្រោងពន្ធគយដោយមិនមានការជូនដំណឹងទាន់ពេលវេលាដល់សាធារណជន។
    - បើកចំហគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIPs) ជាសាធារណៈ និងផ្តល់នូវបញ្ជីអ្នកទទួលផល និងទិន្នន័យសរុបដែលទាក់ទងនឹងការលើកទឹកចិត្តស្តីពីពន្ធ និងអត្ថប្រយោជន៍ផ្សេងៗទៀតដែលស្ថិតនៅក្រោមកម្មវិធីគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។
- បង្កើនសេវាកម្មតាមអនឡាញ និងសេវាសាធារណៈនៃច្រកចេញចូលតែមួយ ដើម្បីកាត់បន្ថយបន្ទុកការិយាធិបតេយ្យ និងការចំណាយទាក់ទងនឹងការធ្វើជំនួញនៅកម្ពុជា ជាពិសេសសម្រាប់សហគ្រាសធុនតូច និងមធ្យមហើយបង្កើនការសម្របសម្រួល ការឆ្លើយតប និងគណនេយ្យភាពពីក្រសួងពាក់ព័ន្ធ។


អង្គការតម្លាភាពកម្ពុជា
ផ្ទះលេខ ៣ ផ្លូវលេខ ៣៩០
សង្កាត់បឹងកេងកង ៣ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

(+855) 23 214 430

*Website: www.ticambodia.org*
*Global website: www.transparency.org*